**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការខេត្តព្រះសីហនុ**
សាលក្រម
លេខ ៩៧ ចុះថ្ងៃទី ១៥
ខែ វិច្ឆិកា ឆ្នាំ ២០០៤
សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩៥ ចុះថ្ងៃទី ៣១
ខែ ឧសភា ឆ្នាំ ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការខេត្តព្រះសីហនុ**

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជំរះ**
លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**
លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**
លោក [redacted] ជាក្រឡាបញ្ជីសវនាការ

**មេធាវី**
លោក [redacted] ទី មេធាវីការពារជនជាប់ចោទឈ្មោះ ស ស, ស រ

សាលក្រមនេះចូលជាស្ថាពរហើយ នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រុងភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រឡាបញ្ជី
[redacted]

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៥ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ ៖

១-ស ស ហៅ ឆ ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាលន់ ឃុំនរាយ ស្រុកឈូក ខេត្តកំពត មានទីលំនៅសព្វថ្ងៃភូមិ៥ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីកម្មករ ឪពុកឈ្មោះ ឡ ស (រ) ម្តាយឈ្មោះ ខ ផ (រ) នៅលីវ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ។

២-ស រ ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាលន់ ឃុំនរាយ ស្រុកឈូក ខេត្តកំពត មានទីលំនៅសព្វថ្ងៃភូមិ៥ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីកម្មករសំណង់ ឪពុកឈ្មោះ ម ខ (រ) ម្តាយឈ្មោះ ស ច (រ) នៅលីវ ចាប់ខ្លួនថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ។

-ជាប់ចោទពីបទប្លន់ ប្រព្រឹត្តនៅភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ពីថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ជនរងគ្រោះឈ្មោះ ស ម ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ របររកស៊ីរត់ម៉ូតូឌុប មានទីលំនៅក្រុម ២៦ ភូមិ៣ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

CamScanner

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ន ស** ភេទប្រុស អាយុ ៥០ឆ្នាំ របររកស៊ីជាងឈើ មានទីលំនៅក្រុម ២៦ ភូមិ ៣ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៣៧១ ដសត ចុះថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១០៩៣ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតរបស់តុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១១៣៨ ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ការប្រព្រឹត្តទៅរបស់ជនជាប់ចោទមានដូចតទៅ :

-កាលពីថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៥ ឈ្មោះ **ឆ ម**, **ស រ** និង ឈ្មោះ **ស ស** បាននាំគ្នាដើរលេងនៅភូមិថ្មី រហូតដល់ម៉ោង ១០យប់ ឈ្មោះ **ស ស** និង ឈ្មោះ **ស រ** បានហៅម៉ូតូឌុបមកកន្លែងធ្វើការរបស់ខ្លួនវិញនៅអូរឈើទាល ក្រោយពេលជិះមកដល់កន្លែងស្នាក់នៅ ឈ្មោះ **ស ស** បានឱ្យម៉ូតូឌុបឈប់ ស្រាប់តែឈ្មោះ **ស រ** វាយម្ចាស់ម៉ូតូ រួចហើយ **ស ស** ក៏បានស្ទុះទៅវាយទៀតដោយដៃផ្ទាល់ ។ ក្រោយពីវាយម្ចាស់ម៉ូតូឱ្យមានរបួសធ្ងន់មកឈ្មោះ **ស រ** បានបញ្ជាឈ្មោះ **ខ ម** ដែលជាអ្នកចេះបើកម៉ូតូឱ្យបើកឌុបពួកខ្លួនទៅកន្លែងថ្លឹងឡាន ។ ដោយការខ្លាចអ្នកទាំងពីរធ្វើបាបខ្លួន **ឆ ម** ក៏ស្តាប់បង្គាប់ **ស រ** និង **ស ស** បើកម៉ូតូទៅដល់កន្លែងថ្លឹងឡានអូរឧកញ៉ាហេង ហើយត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ **ស ស** បានឆ្លើយថា : នៅថ្ងៃកើតហេតុ ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ វេលាម៉ោង ១០យប់ខ្ញុំទាំងបីនាក់មានឈ្មោះ **ស រ**, **ឆ ម** និង ខ្ញុំ **ស ស** បានជួលម៉ូតូជនរងគ្រោះជិះពីភូមិថ្មី មកភូមិទឹកស្អាត ហួសអារីស្តុនបន្តិចជិតស្ពានត្រង់មានដើមកាស្យា អ្នកម៉ូតូឌុបលែងទៅមុខទៀត ខ្ញុំក៏មានគំនិតប្លន់ពីព្រោះខ្ញុំជំពាក់លុយគេ ហើយខ្វះលុយទៅផ្ទះវិញ ទើបខ្ញុំទាំងបីនាក់មានគំនិតប្លន់ ដើម្បីយកម៉ូតូទៅលក់បានប្រាក់យកទៅផ្ទះ ។ ពេលនោះឈ្មោះ **ស រ** វាយមុនគេ បន្ទាប់មកឈ្មោះ **ខ ម** ចំណែកខ្ញុំវាយក្រោយ ។ ពេលវាយជនរងគ្រោះ ខ្ញុំបាទទាំងអស់គ្នាបានវាយដោយដៃមិនប្រើអាវុធទេ ពេលជនរងគ្រោះលែងតដៃជាមួយពួកខ្ញុំ ពួកខ្ញុំក៏ឈប់វាយ ពេលនោះឈ្មោះ **ឆ ម** ជាអ្នកបើកម៉ូតូ ខ្ញុំពីរនាក់ **រ** ជិះពីក្រោយ ។ ពេលទៅដល់អូរឧកញ៉ាហេង កន្លែងថ្លឹងឡានក៏ត្រូវប៉ូលីសឃាត់ខ្លួនពួកខ្ញុំទាំងបីនាក់តែម្តង ។

-ជនជាប់ចោទឈ្មោះ **ស រ** បានឆ្លើយថា : ខ្ញុំបាទបានដើរលេងនៅភូមិថ្មី មានគ្នាបីនាក់ ១-ឈ្មោះ **ស ស** ២-ឈ្មោះ **ឆ ម** ៣-រូបខ្ញុំ ។ តំបូងពួកខ្ញុំទៅទិញផ្លែសៅម៉ាវនៅផ្សារ៉ូយាល់ រួចពួកខ្ញុំដើរមកដល់កែងភូមិថ្មី មានអ្នកម៉ូតូឌុបហៅពួកខ្ញុំឱ្យជិះម៉ូតូគាត់ ខ្ញុំទាំងបីនាក់ក៏ជិះម៉ូតូពីភូមិថ្មីមកដល់ពាក់កណ្តាលផ្លូវ ស្រាប់តែឈ្មោះ **ស ស** បានខ្សឹបប្រាប់ខ្ញុំថា ធ្វើសកម្មភាពប្លន់ម៉ូតូពេលទៅដល់ខាងក្រោយអារីស្តុន ។ ពេលទៅដល់ទិសដៅ ម៉ូតូនោះឈប់លែងទៅមុខទៀត ពេលនោះពួកខ្ញុំទាំងបីនាក់ចុះពីលើម៉ូតូ ហើយខ្ញុំបានរុញម្ចាស់ម៉ូតូចេញពីម៉ូតូ ឯឈ្មោះ **ស ស** និង **ឆ ម** វាយម្ចាស់ម៉ូតូរហូតដល់ម្ចាស់ម៉ូតូលែងរើ ពេលនោះ **ឆ ម** ជាអ្នកបើកម៉ូតូ ខ្ញុំអង្គុយកណ្តាល ឯ **ស ស** អង្គុយក្រោយ គេនាំគ្នាជិះម៉ូតូហួសដល់កន្លែងថ្លឹងឡាន ទើបប៉ូលីសឃាត់ខ្លួនទាំងបីនាក់តែម្តង ។

CS CamScanner

-តុលាការអានអំណានចម្លើយឈ្មោះ ឆ ម ដែលមានខ្លឹមសារទាំងស្រុងថា : នៅយប់កើតហេតុ ខែ ឧសភា ឆ្នាំ ២០០៤ ខ្ញុំបាទផ្ទាល់ ស ស និង ស រ បានដើរលេងនៅភូមិថ្មីរហូតដល់ម៉ោង ១០យប់ ឈ្មោះ ស ស និង ឈ្មោះ ស រ បានហៅម៉ូតូឌុបជិះពីភូមិថ្មីទៅអូរឈើទាលវិញក្នុងតម្លៃ ៥.០០០រៀល ដោយជិះគ្នាបីនាក់ ។ ឈ្មោះ ស ស ឱ្យខ្ញុំជិះមុខបន្ទាប់មកឈ្មោះ ស ស ឯក្រោយគេឈ្មោះ ស រ ពេលជិះមកដល់ខាងកើតអារីស្តុន ស្រាប់តែឈ្មោះ ស ស ហៅម៉ូតូឱ្យឈប់ ពេលម៉ូតូឈប់ហើយឈ្មោះ ស រ បានស្ទុះទៅវាយម្ចាស់ម៉ូតូ បន្ទាប់មកឈ្មោះ ស ស និង ស រ បានឱ្យខ្ញុំបើកម៉ូតូ ។ ពេលខ្ញុំបើកម៉ូតូដល់កន្លែងថ្នឹងឡានទៅអូរចំណារ ស្រាប់តែសមត្ថកិច្ចឃាត់ខ្លួនខ្ញុំទាំងបីនាក់តែម្តង ។ ខ្ញុំសូមបញ្ជាក់ថា គំរោងប្លន់នេះ ស ស ជាអ្នកបបួលគេមុន ខ្ញុំទើបតែដឹងក្នុងពេលកំពុងជិះម៉ូតូជាមួយគ្នា ។

-ឈ្មោះ ស ម ជាជនរងគ្រោះបានឆ្លើយក្នុងពេលសវនាការថា : ខ្ញុំបានឌុបមនុស្សបីនាក់ ។ បីនាក់នេះបានឱ្យខ្ញុំឌុបពួកគេទៅគោពីរក្នុងតម្លៃ ៥០០០រៀល ពេលដឹកដល់គោពួកវាថា ទៅអារីស្តុន ខ្ញុំក៏បន្តដឹកវាទៅមុខទៀតលុះដល់ចំណុចខាងកើតអារីស្តុនត្រង់កន្លែងស្ងាត់គ្មានមនុស្ស . ស្រាប់តែពួកវាទាំងបីនាក់បានព្រួតគ្នាវាយខ្ញុំរហូតដល់ខ្ញុំដួលទៅលើដី ទើបពួកវាទាំងបីនាក់យកម៉ូតូខ្ញុំជិះចេញត្រឡប់មកខាងក្រោយវិញ ។

-ឈ្មោះ ឧ ស ជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយក្នុងពេលសវនាការថា : ឈ្មោះ ស ម នេះត្រូវជាក្មួយរបស់ខ្ញុំត្រូវបានចោរប្លន់ប្រាកដមែន ។ ម៉ូតូនេះជារបស់ខ្ញុំទុកឱ្យក្មួយរត់ឌុបគ្រាន់រកលុយចិញ្ចឹមជីវិត ។ ពេលកើតហេតុខ្ញុំបាទពុំបានដឹងទេ លុះខ្លួនមកដល់សង្កាត់លេខ៤ ទើបដឹង ។

-ក្នុងរឿងនេះខ្ញុំសូមទាមទារសំណងថ្លៃព្យាបាលរបួស និង ជម្ងឺចិត្តពីជនល្មើសចំនួន ១.០០០.០០០រៀល ( មួយលានរៀល ) និង សុំឱ្យតុលាការផ្តន្ទាទោសជនល្មើសទៅតាមច្បាប់ ។

-អយ្យការបានធ្វើសេចក្តីសន្និដ្ឋានទោសដោយចោទប្រកាន់លើជនជាប់ចោទឈ្មោះ ស ស និង ឈ្មោះ ស រ ពីបទប្លន់ ប្រព្រឹត្តនៅភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារថា : ជនជាប់ចោទជាមនុស្សអវិជ្ជា មិនធ្លាប់មានទោសពីមុនមក ការពិចារណាមិនបានច្បាស់លាស់ សុំតុលាការជួយបន្ធូរបន្ថយទោសដល់ជនជាប់ចោទឱ្យបានស្រាលផង ។

-ជនជាប់ចោទទាំងពីរបានសំណូមពរជាចុងក្រោយថា សូមលោកតុលាការមេត្តាជួយបន្ធូរបន្ថយទោសឱ្យខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយឱ្យការរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយឱ្យការរបស់សាក្សី

-ក្រោយពីបានស្តាប់ការសួរដេញដោលនាពេលសវនាការ

-ក្រោយពីបានពិនិត្យឯកសារ និង ភស្តុតាងនានាដែលទាក់ទិនក្នុងរឿងនេះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**<u>ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ</u>**

**<u>យល់ឃើញថា</u>**

CS CamScanner

-នៅថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ពិតជាមានអំពើប្លន់ ដែលបណ្តាលឱ្យជនរងគ្រោះឈ្មោះ **ស ម** រងរបួសជាទម្ងន់ នៅចំណុចភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ប្រាកដមែន ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ **ស ស** និង ឈ្មោះ **ស រ** បានសារភាពក្នុងពេលសវនាការនេះថា ពួកខ្លួនបានហៅម៉ូតូឌុបជិះពីភូមិថ្មីទៅអារីស្កុន ហើយម៉ូតូឌុបមិនហ៊ានទៅទៀតក៏ឈប់ ឆ្លៀតពេលនោះខ្លួនក៏ចាប់ផ្តើមធ្វើសកម្មភាពប្លន់វាយជនរងគ្រោះ រួចអូសយកទៅដាក់ចោលនៅព្រៃក្បែរនោះ ។

-ក្រោយពេលជនជាប់ចោទប្លន់ជនរងគ្រោះបានសំរេចហើយ ក៏បានជិះម៉ូតូនេះគេចខ្លួន តែដោយសមត្ថកិច្ចមានការប្រុងប្រយ័ត្នទើបអាចទប់ស្កាត់បទល្មើសនេះបានទាន់ពេលវេលា ព្រមទាំងចាប់ជនទាំងពីរនាក់នេះបាន និង ដកហូតវត្ថុតាង " ម៉ូតូ " ជាក់ស្តែងទៀតផង ។

-ភស្តុតាងមានលក្ខណៈស៊ីសង្វាក់គ្នា ដែលអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ **ស ស** ឈ្មោះ **ស រ** ពិតជាបានប្លន់ទ្រព្យសម្បត្តិប្រជាជន " ម៉ូតូ " កាលពីថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសនេះមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-អំពើរបស់ជនជាប់ចោទទាំងពីរនាក់នេះបានស្តែងចេញយ៉ាងសកម្មបង្កឱ្យមានព្យសនកម្ម និង អន្តរាយដល់សន្តិសុខសង្គមយ៉ាងធ្ងន់ធ្ងរ ។ កម្មវិបាកនៃអំពើនេះបណ្តាលឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពបុគ្គល និង ទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាជន ដែលច្បាប់បានការពារ ។

-ជនជាប់ចោទឈ្មោះ **ស ស** និង ឈ្មោះ **ស រ** ជាសមត្ថជនមានស្មារតីជានាល្អ មានសមត្ថភាពទទួលខុសត្រូវនូវរាល់អំពើប្រព្រឹត្តរបស់ខ្លួន ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ស ស** និង ឈ្មោះ **ស រ** ពីបទប្លន់ ប្រព្រឹត្តនៅភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីបានប្តឹងសុំទាមទារសំណងជាប្រាក់មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

-ឈ្មោះ **ខ ម** ត្រូវបានលោកចៅក្រមស៊ើបអង្កេតដោះលែងឱ្យមានសេរីភាពវិញហើយ ។

## <u>យល់ឃើញថា</u>

-ឈ្មោះ **ស ស** និងឈ្មោះ **ស រ** ជាមនុស្សមិនចេះអក្សរ ហើយមិនដែលធ្លាប់មានទោសពីមុនមក ការប្រព្រឹត្តនេះដោយសារខ្វះការពិចារណា ដែលស្ថានភាពនេះអាចឱ្យតុលាការយកមកពិចារណាជាស្ថានសំរាលទោសក្នុងការវិនិច្ឆ័យសេចក្តីបាន ។

## <u>ហេតុដូច្នេះតុលាការវិនិច្ឆ័យសេចក្តី</u>

១-<u>ផ្តន្ទាទោសឈ្មោះ</u> :

ក-**ស ស** ហៅ **ធ** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាលន់ ឃុំនរាយ ស្រុកឈូក ខេត្តកំពត មានទីលំនៅសព្វថ្ងៃភូមិ ៥ សង្កាត់ ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីកម្មករ ឪពុកឈ្មោះ **ឡ ស** ( រ ) ម្តាយឈ្មោះ **ខ ដ** ( រ ) នៅលីវ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ " ប្រាំ " គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ។

CamScanner

ខ-សេ រ ភេទប្រុស អាយុ ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិតាលន់ ឃុំនរាយ ស្រុកឈូក ខេត្តកំពត មានទីលំនៅសព្វថ្ងៃភូមិ៥ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីកម្មករសំណង់ ឪពុកឈ្មោះ ម ខ ( រ ) ម្តាយឈ្មោះ ស ឃ ( រ ) នៅលីវ ចាប់ខ្លួនថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ដាក់ពន្ធនាគារកំណត់ ០៥ឆ្នាំ " ប្រាំឆ្នាំ " គិតពីថ្ងៃចាប់ខ្លួន ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ ។

ពីបទប្លន់ ប្រព្រឹត្តនៅភូមិ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ផ្តន្ទាទោសតាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

២-ឱ្យឈ្មោះ ស ស និង ឈ្មោះ ស រ រួមគ្នាសងសំណងថ្លៃថ្នាំព្យាបាលរបួស និង ជម្ងឺចិត្តជាទឹកប្រាក់ ចំនួន ១.០០០.០០០រៀល " មួយលានរៀល " ទៅឱ្យជនរងគ្រោះឈ្មោះ ស ម ដែលមានឈ្មោះ ន ស ជាដើមបណ្តឹងរដ្ឋប្បវេណី គិតចាប់តាំងពីពេលសាលក្រមនេះចូលជាស្ថាពរ ។

ក្នុងករណីទណ្ឌិតគ្មានប្រាក់សងធនទណ្ឌទេ ត្រូវដាក់គុកបង្ខំដល់រូបកាយតាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៣-វត្ថុតាងរួមមានម៉ូតូម៉ាកហុងដាសេ ១០០ សេរី៩៧ លេខតួ និង លេខម៉ាស៊ីន ១០២២៤៩៦ ចំនួន ០១គ្រឿងត្រូវប្រគល់ឱ្យ ន ស ប្រើប្រាស់ជាសម្បត្តិផ្ទាល់ខ្លួនឡើងវិញ គិតចាប់ពីពេលនេះតទៅ ។

សាលក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ ជនរងគ្រោះ និង ដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ក្រឡាបញ្ជី

[redacted]

ចៅក្រមជំនុំជំរះ

[redacted]

CS CamScanner